# ព្រះរាជក្រម

នស/រកម/០១១៧/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល
លេខ ២០៧
ថ្ងៃទី ១៧/០១ ឆ្នាំ ២០១៧ ម៉ោង ១៥:៣០
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១៥

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ
## ផ្នែកទី ១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១.-**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ។ ការអនុវត្តនេះ សម្រេចបានលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោម ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ | ឆ្នាំ២០១៥ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = (I.១ + II.១) | ១៥ ១៣៥ ២៣០,០ | ១៦ ២២៩ ២០៣,៨ | ១០៧,២% | + ១ ០៩៣ ៩៧៣,៨ |
| សរុបចំណាយ = (I.២ + II.២) | ១៥ ០៣៥ ២២៩,០ | ១៤ ៦៦០ ១៤៧,១ | ៩៧,៥% | -៣៧៥ ០៨១,៩ |
| អតិរេកនៃថវិកា | + ១០០ ០០១,០ | + ១ ៥៦៩ ០៥៦,៧ | | |
| I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | ១១ ៤៤៨ ២៣០,០ | ១២ ៥០៨ ៧៩៨,៥ | ១០៩,៣% | + ១ ០៦០ ៥៦៨,៥ |
| • ចំណូលចរន្ត | ១១ ០១៤ ៦៤៤,០ | ១២ ២៤៥ ៦៣៩,១ | ១១១,២% | + ១ ២៣០ ៩៩៥,១ |
| • ចំណូលមូលធន | ៤៣៣ ៥៨៦,០ | ២៦៣ ១៥៩,៤ | ៦០,៧% | -១៧០ ៤២៦,៦ |
| + ចំណូលមូលធនក្នុងប្រទេស | ១៣៣ ៥៨៦,០ | ១២១ ៣៨៣,១ | ៩០,៩% | -១២ ២០២,៩ |
| + ចំណូលមូលនិធិទ្រទ្រង់ថវិកា | ៣០០ ០០០,០ | ១៤១ ៧៧៦,៣ | ៤៧,៣% | -១៥៨ ២២៣,៧ |
| I.២.ចំណាយថវិកា | ១១ ៣៤៨ ២២៩,០ | ១០ ៩៣៩ ៧៤១,៨ | ៩៦,៤% | -៤០៨ ៤៨៧,២ |
| • ចំណាយចរន្ត | ៩ ២៧៥ ១៦១,០ | ៩ ០៦៦ ៨០៤,៨ | ៩៧,៨% | -២០៨ ៣៥៦,២ |
| • ចំណាយមូលធន | ២ ០៧៣ ០៦៨,០ | ១ ៨៧២ ៩៣៧,០ | ៩០,៣% | -២០០ ១៣១,០ |
| II.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៦៨៧ ០០០,០ | ៣ ៧២០ ៤០៥,៣ | ១០០,៩% | + ៣៣ ៤០៥,៣ |
| II.២.ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៦៨៧ ០០០,០ | ៣ ៧២០ ៤០៥,៣ | ១០០,៩% | + ៣៣ ៤០៥,៣ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ២.–

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង"**ក**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ ត្រូវបានបង្ហាញលម្អិតតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង"**ខ**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥: ចំពោះចំណូលត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង"**ក**" និងចំពោះចំណាយត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង"**ខ២**" ដូចមានភ្ជាប់ជាមួយច្បាប់នេះ ។

# ផ្នែកទី ២

# កិច្ចប្រតិបត្តិការចំណូល និងចំណាយថវិកាអនុវត្តឆ្លងកាត់រតនាគារជាតិ

## មាត្រា ៣.–

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ សម្រេចបានលទ្ធផលដូចតទៅ ៖

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១១ ៤៤៨ ២៣០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន........................ ១២ ៥០៨ ៧៩៨,៥ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុចំនួន........................................ ១ ០៦០ ៥៦៨,៥ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១១ ០១៤ ៦៤៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន........................ ១២ ២៤៥ ៦៣៩,១ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន........................ ១ ២៣០ ៩៩៥,១ លានរៀល ។

២. ចំណូលមូលធន

- ច្បាប់ហិរញ្ញវត្ថុ.................................................. ៤៣៣ ៥៨៦,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.................................. ២៦៣ ១៥៩,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ១៧០ ៤២៦,៦ លានរៀល ។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១៣៣ ៥៨៦,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១២១ ៣៨៣,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ១២ ២០២,៩ លានរៀល ។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ..........................................៣០០ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១៤១ ៧៧៦,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន...................... ១៥៨ ២២៣,៧ លានរៀល ។

## មាត្រា ៤.-

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥ សម្រេចបានលទ្ធផលដូចតទៅ ៖

- ច្បាប់ហិរញ្ញវត្ថុ..........................................១១ ៣៤៨ ២២៩,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១០ ៩៣៩ ៧៤១,៨ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុចំនួន..........................................៤០៨ ៤៨៧,២ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ.......................................... ៩ ២៧៥ ១៦១,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ៩ ០៦៦ ៨០៤,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២០៨ ៣៥៦,២ លានរៀល ។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ.......................................... ២ ០៧៣ ០៦៨,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១ ៨៧២ ៩៣៧,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២០០ ១៣១,០ លានរៀល ។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ៦៣៦ ៥០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១ ៥៤២ ៨៦៨,៨ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..........................៩៣ ៦៣១,២ លានរៀល ។